N: 42
15-11-97

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

* * *

ឆ្នាំទី ៥ លេខ ៤២ ថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧

រាជកិច្ច

រួមមាន :

- ច្បាប់
- ក្រម-ក្រឹត្យ
- អនុក្រឹត្យ
- ប្រកាស
- សេចក្តីសំរេច
- សារាចរ

ផ្សាយចេញពីទីស្តីការគណៈរដ្ឋមន្ត្រីរៀងរាល់សប្តាហ៍

មាតិកា

I .ខុទ្ទកាល័យព្រះមហាក្សត្រ

១_ព្រះរាជក្រម

៦_១១_១៩៩៧ _ព្រះរាជក្រម ជស/រកម/១១៩៧/០៥ ច្បាប់ស្តីពីលក្ខន្តិកៈទូទៅចំពោះយោធិន នៃកងយោធពលខេមរភូមិន្ទ ២៤១១

១២_១១_១៩៩៧ _ព្រះរាជក្រម ជស/រកម/១១៩៧/០៦ ច្បាប់ស្តីពីការរំលូតកូន ២៤៣០

២_ព្រះរាជក្រឹត្យ

៥_១១_១៩៩៧ _ព្រះរាជក្រឹត្យ នស/រកត/១១៩៧/២២៣ តែងតាំង ឯកឧត្តម អ៊ិត លីហេង ជាទីប្រឹក្សាផ្ទាល់ ឯកឧត្តម នាយករដ្ឋមន្ត្រីទី១ ២៤៣៥

៥_១១_១៩៩៧ _ព្រះរាជក្រឹត្យ ជស/រកត/១១៩៧/២២៥ តែងតាំងឯកឧត្តម ទី រតនា ជាទីប្រឹក្សាផ្ទាល់ ឯកឧត្តមនាយករដ្ឋមន្ត្រីទី១ ២៤៣៦

៥_១១_១៩៩៧ _ព្រះរាជក្រឹត្យ ជស/រកត/១១៩៧/២២៦ តែងតាំងឯកឧត្តម ប្រាក់ ជិន ជាទីប្រឹក្សាផ្ទាល់ ឯកឧត្តមនាយករដ្ឋមន្ត្រីទី១ ២៤៣៧

៥_១១_១៩៩៧ _ព្រះរាជក្រឹត្យ ជស/រកត/១១៩៧/២២៧ តែងតាំងឯកឧត្តម ទាវ អ៊ាវហួ ជាទីប្រឹក្សាផ្ទាល់ ឯកឧត្តមនាយករដ្ឋមន្ត្រីទី១ ២៤៣៨

៥_១១_១៩៩៧ _ព្រះរាជក្រឹត្យ ជស/រកត/១១៩៧/២២៨ តែងតាំងឯកឧត្តមបណ្ឌិត សុខ ម៉ាធឿន ជាទីប្រឹក្សាផ្ទាល់ ឯកឧត្តមនាយករដ្ឋមន្ត្រីទី១ ២៤៣៩

៥_១១_១៩៩៧ _ព្រះរាជក្រឹត្យ ជស/រកត/១១៩៧/២២៩ តែងតាំងឯកឧត្តម ឌុយ សារិនដេត ជាទីប្រឹក្សាផ្ទាល់ ឯកឧត្តមនាយករដ្ឋមន្ត្រីទី១ ២៤៤០

៥_១១_១៩៩៧ _ព្រះរាជក្រឹត្យ ជស/រកត/១១៩៧/២៤២ តែងតាំងជិទាវ ទាវ ចំនួថាណា
ជាទីប្រឹក្សាផ្ទាល់ ឯកឧត្តមនាយករដ្ឋមន្ត្រីទី១ ២៤៥៣
៥_១១_១៩៩៧ _ព្រះរាជក្រឹត្យ ជស/រកត/១១៩៧/២៤៥ តែងតាំងលោក សៃ សាមុត
ជាសមាជិកទីប្រឹក្សាភិបាល និងគណៈកម្មាធិការប្រតិបត្តិ មូលនិធិសង្គម
ជំនួសលោក អ៊ុង ធីត ២៤៥៤

II .រាជរដ្ឋាភិបាល

សេចក្តីសំរេច

១១_១១_១៩៩៧ _សេចក្តីសំរេច លេខ ៤៧ សសរ ស្តីពីការបង្កើតគណៈកម្មការសំរបសំរួល
ដើម្បីអភិវឌ្ឍន៍ផ្នែកផ្គត់ផ្គង់ទឹកស្អាត និងអនាម័យ ២៤៥៥
១២_១១_១៩៩៧ _សេចក្តីសំរេច លេខ ៤៨ សសរ ស្តីពីការផ្ទេរសិទ្ធិ ២៤៥៧

III .ការងារបណ្តាក្រសួង

១_ទីស្តីការគណៈរដ្ឋមន្ត្រី

សេចក្តីសំរេច

១១_១១_១៩៩៧ _សេចក្តីសំរេច លេខ ១៨ សសរ ស្តីពីបង្កើតច្រកទ្វារអន្តរជាតិ
នៅអាកាសយាន ដ្ឋានខេត្តសៀមរាប ២៤៥៩

២_ទីស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

ប្រកាស

១២_១១_១៩៩៧ _ប្រកាស លេខ ៣០១/៩៧ ពម.ប្រក. ស្តីពីការតែងតាំងមន្ត្រីរាជការ ២៤៦១

៣_ទីស្តីការក្រសួងធម្មការ និងសាសនា

ប្រកាស

១៥_១២_១៩៩៧ _ប្រកាស លេខ ២២២ កធស.ប្រក. ស្តីពីការតែងតាំងមន្ត្រីរាជការ ២៤៦៣

I - ខុទ្ទកាល័យព្រះមហាក្សត្រ

១_ព្រះរាជក្រម

ព្រះរាជក្រម ជស/រកម ១១៩៧/០៥

យើង

ព្រះបាទសម្ដេចព្រះ នរោត្ដម សីហនុ
រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍
និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
ព្រះចៅក្រុងកម្ពុជាធិបតី

* * *

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស /៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្ដីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត ១០៩៤/៩០ ចុះថ្ងៃទី៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្ដីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត /០៨៩៧/១៤៧ ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ ១៩៩៧ ស្ដីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងការពារជាតិ

-តាមសេចក្តីក្រាបបង្គំទូលស្នើសុំ អំពីឯកឧត្តមនាយករដ្ឋមន្ត្រីទី១ និងសម្តេចនាយករដ្ឋមន្ត្រីទី២ និងអំពីសហរដ្ឋមន្ត្រីក្រសួងការពារជាតិ

ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីលក្ខន្តិកៈ ទូទៅចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ ដែលរដ្ឋសភាបាន អនុម័ត កាលពីថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ ១៩៩៧ នាសម័យប្រជុំលើកទី៨ នីតិកាលទី១ ដែលមានសេចក្តីទាំងស្រុងដូចតទៅ :

ច្បាប់

ស្តីពី

លក្ខន្តិកៈទូទៅចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ

ជំពូកទី ១

បទប្បញ្ញត្តិទូទៅ

មាត្រា១.- កងយោធពលខេមរភូមិន្ទ មានភារកិច្ចបំរើ ប្រទេសជាតិ ។ បេសកកម្មរបស់កងយោធពលខេមរភូមិន្ទ គឺត្រូវរៀបចំប្រើប្រាស់កម្លាំងកងយោធពលខេមរភូមិន្ទ ដើម្បីការពារ កសាងមាតុភូមិ និងដើម្បីផលប្រយោជន៍ដ៏ខ្ពង់ខ្ពស់ របស់ប្រទេសជាតិ ។

ក្នុងកាលៈទេសៈចាំបាច់ កងយោធពលខេមរភូមិន្ទនឹងអាចចូលរួមក្នុងការការពារសន្តិសុខសាធារណៈនិងជាជំនួយដល់ប្រជាពលរដ្ឋ ដែលជួបការលំបាក ឬ មានអាសន្នមហន្តរាយ ។

យោធិនត្រូវគោរពវិន័យយ៉ាងម៉ឺងម៉ាត់ ភក្តីភាពនិងក្លាហានហ៊ានធ្វើពលីកម្ម នៅគ្រប់កាលៈទេសៈទាំងអស់ចំពោះជាតិមាតុភូមិ ។

យោធិនត្រូវបំពេញករណីយកិច្ចជាចាំបាច់ ដើម្បីសក្តិសមទៅនឹងការគោរពស្រឡាញ់ពីសំណាក់ប្រជាពលរដ្ឋ ។

លក្ខន្តិកៈទូទៅនេះជានាសិទ្ធិ សេរីភាពនិងចែងអំពីកាតព្វកិច្ចចំពោះយោធិនគ្រប់រូប រួមមាន :

១_យោធិនអាជីព

២_យោធិនជាប់កិច្ចសន្យា

មាត្រា២._យោធិនទាំងឡាយត្រូវស្ថិតនៅក្នុងបទប្បញ្ញត្តិរបស់លក្ខន្តិកៈទូទៅនេះ ។

ក្រុមប្រឹក្សាយោធាត្រូវបានបង្កើតដើម្បីពិនិត្យបទដ្ឋានច្បាប់ទាំងឡាយដែលទាក់ទងទៅនឹងបញ្ហាយោធា ។

ការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាយោធានេះ ត្រូវកំណត់ដោយអនុក្រឹត្យ ។

បទវិន័យទូទៅសំរាប់កងយោធពលខេមរភូមិន្ទ ត្រូវកំណត់ដោយអនុក្រឹត្យ ។

មាត្រា៣._ កងយោធពលខេមរភូមិន្ទមានកងទ័ពបីប្រភេទ :

១_កងទ័ពជើងគោក

២_កងទ័ពជើងអាកាស

៣_កងទ័ពជើងទឹក

មាត្រា៤._ ឋានានុក្រមរបស់កងយោធពលខេមរភូមិន្ទមាន ៣ ថ្នាក់ :

១_ពលទាហាន

២_នាយទាហានរង

៣_នាយទាហាន

មាត្រា៥._ នៅក្នុងលំដាប់ថ្នាក់ ឋានន្តរសក្តិយោធិនទូទៅមាន :

១_ឋានន្តរសក្តិពលទាហានមាន :

កងទ័ពជើងគោកនិងកងទ័ពជើងអាកាស	**កងទ័ពជើងទឹក**
_ពលទោ	_នាវិកទោ
_ពលឯក	_នាវិកឯក
_នាយទោ	_ចក្របាលរងទោ
_នាយឯក	_ចក្របាលរងឯក

២_ឋានន្តរសក្តិនាយទាហានរងមាន :

កងទ័ពជើងគោកនិងកងទ័ពជើងអាកាស	**កងទ័ពជើងទឹក**
_ពលបាលត្រី	_ចក្របាលត្រី
_ពលបាលទោ	_ចក្របាលទោ
_ពលបាលឯក	_ចក្របាលឯក
_ព្រិន្ទបាលទោ	_នាយចក្របាលទោ
_ព្រិន្ទបាលឯក	_នាយចក្របាលឯក

៣_ថ៉ានន្តរសក្តិនាយទាហានមាន :

៣.១_នាយទាហានថ្នាក់អនុសេនីយ៍មាន :

កងទ័ពជើងគោកនិងកងទ័ពជើងអាកាស	កងទ័ពជើងទឹក
_នាយចំណង់	_នាយនាវីចំណង់
_អនុសេនីយ៍ត្រី	_អនុនាវីត្រី
_អនុសេនីយ៍ទោ	_អនុនាវីទោ
_អនុសេនីយ៍ឯក	_អនុនាវីឯក

៣.២_នាយទាហានថ្នាក់វរសេនីយ៍មាន :

កងទ័ពជើងគោកនិងកងទ័ពជើងអាកាស	កងទ័ពជើងទឹក
_វរសេនីយ៍ត្រី	_វរនាវីត្រី
_វរសេនីយ៍ទោ	_វរនាវីទោ
_វរសេនីយ៍ឯក	_វរនាវីឯក

៣.៣_នាយទាហានថ្នាក់ឧត្តមសេនីយ៍មាន :

កងទ័ពជើងគោកនិងកងទ័ពជើងអាកាស	កងទ័ពជើងទឹក
_ឧត្តមសេនីយ៍ត្រី	_ឧត្តមនាវីត្រី
_ឧត្តមសេនីយ៍ទោ	_ឧត្តមនាវីទោ
_ឧត្តមសេនីយ៍ឯក	_ឧត្តមនាវីឯក
_នាយឧត្តមសេនីយ៍	_នាយឧត្តមនាវី

មាត្រា៦._យោធិនស្ថិតនៅក្នុងអង្គធំៗពីរ :

_អង្គទី១ : ប្រមូលផ្តុំយោធិននៃកងទ័ពជើងគោក កងទ័ពជើងអាកាស និងកងទ័ពជើងទឹក ដែលជាកំលាំងសំរាប់ប្រើប្រាស់ប្រតិបត្តិការសឹក ។

_អង្គទី២ : ប្រមូលផ្តុំយោធិនដែលបំរើការនៅក្នុងសេវារដ្ឋបាលរបស់កងទ័ព ។ អង្គធំៗទាំងពីរនេះ អាចត្រូវបំបែកចេញជាប្រភេទកងទ័ព ឬ ឯកទេសជំនាញ ។

មាត្រា៧._ការផ្លាស់ប្តូរប្រភេទកងទ័ព ឬឯកទេសជំនាញរបស់យោធិន ត្រូវកំណត់ដោយអនុក្រឹត្យ ឬ ដោយប្រកាសរបស់ក្រសួងការពារជាតិ ។

មាត្រា៨._ការតម្លើងឋានន្តរសក្តិត្រូវប្រព្រឹត្តទៅតាមលំដាប់មួយសក្តិម្តងៗ ហើយពុំអាចមានការតែង តាំងជាងារកិត្តិយសឡើយ ។

ជំពូកទី ២

សិទ្ធិ ភារកិច្ច និងភារកិច្ចទទួលខុសត្រូវ

មាត្រា៩._យោធិនមានសិទ្ធិនិងសេរីភាព ដូចប្រជាពលរដ្ឋដទៃទៀត ។ ក៏ប៉ុន្តែការប្រើសិទ្ធិ និងសេរី ភាពខ្លះ ត្រូវមានកំរិតស្របតាមល័ក្ខខ័ណ្ឌដែលមានចែងក្នុងច្បាប់នេះ ។

យោធិនត្រូវមានអព្យាក្រឹត្យភាពក្នុងមុខនាទី ក្នុងសកម្មភាពការងារនិងហាមឃាត់ ការប្រើមុខងារនិងប្រើប្រាស់សំភារៈរបស់រដ្ឋ ដើម្បីបំរើសកម្មភាពនយោបាយណាមួយ ។

មាត្រា១០._យោធិនម្នាក់ៗអាចមានគំនិត ឬជំនឿដែលមានលក្ខណៈជាទស្សនវិជ្ជាឬនយោបាយ ផ្ទាល់ខ្លួនបាន ប៉ុន្តែពុំអាចសំដែងជាសាធារណៈបានឡើយ ។ វិធាននេះមិនហាមឃាត់ ដល់ការប្រតិបត្តិដោយសេរីនូវជំនឿសាសនានៅក្នុងបរិវេណយោធា និងនៅលើនាវានៃ កងទ័ពជើងទឹកឡើយ ។

យោធិនដែលចង់បកស្រាយជាសាធារណៈ ជាអាទិ៍ការសរសេរ ការធ្វើសន្និសីទ ឬ សេចក្តីថ្លែងការណ៍នូវបញ្ហានយោបាយ ការសម្ភាសន៍យោធាឬការចោទប្រកាន់ជនបរទេស ឬអង្គការអន្តរជាតិណាមួយ ត្រូវមានការអនុញ្ញាតពីរដ្ឋមន្ត្រីក្រសួងការពារជាតិ ។

មាត្រា១១._ការបញ្ចូលមកក្នុងបរិវេណឬគ្រឹះស្ថានយោធា ក៏ដូចជានៅក្នុងនាវានៃកងទ័ពជើងទឹកនូវ ការផ្សព្វផ្សាយ ទោះមានរូបភាពបែបណាក៏ដោយ ដែលនាំអោយខូចដល់ទឹកចិត្តឬវិន័យ ត្រូវហាមឃាត់ទៅតាមល័ក្ខខ័ណ្ឌ ដែលមានចែងដោយបទវិន័យទូទៅ នៃកងយោធពល ខេមរភូមិន្ទ ។

មាត្រា១២._យោធិនពុំអាចនាំគ្នាបង្កើតជាក្រុមវិជ្ជាជីវៈ ដែលមានលក្ខណៈជាសហជីព ឬចូលរួមជា សមាជិកក្រុមវិជ្ជាជីវៈណាមួយ ដែលមិនសមស្របទៅនឹងវិន័យយោធាបានឡើយ ។

ជំពូកទី ៣

បៀវត្ស និង ប្រាក់បំណាច់ផ្សេងៗ

មាត្រា២១._យោធិនមានសិទ្ធទទួលប្រាក់បៀវត្ស ដែលចំនួនទឹកប្រាក់កំណត់ទៅតាមឋានន្តរសក្តិ លំដាប់ថ្នាក់ គុណវុឌ្ឍិងារ តំណែង និង អតីតភាព ។

យោធិនអាចទទួលនូវប្រាក់បន្ថែមបំណាច់ពិសេសផ្តល់ជូនទៅតាមប្រភេទមុខងារ ដែលខ្លួនបំពេញ ឬហានិភ័យដែលអាចកើតឡើង ។

មាត្រា២២._យោធិនត្រូវបានទទួលរបបសោធននិវត្តន៍និងសោធនបាត់បង់សមត្ថភាពការងារ ដែលបានកំណត់ក្នុងច្បាប់ ស្តីពីរបបសោធននិវត្តន៍និងសោធនបាត់បង់សមត្ថភាពការងារ ចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ ។

មាត្រា២៣._យោធិន អតីតយោធិនអាជីព និងគ្រួសារផ្ទាល់របស់គេ មានសិទ្ធព្យាបាលជំងឺនៅក្នុង មន្ទីរពេទ្យនៃកងយោធពលខេមរភូមិន្ទ ។

ផ្នែក ទី ៤

យោធិនអាជីព

មាត្រា២៤._យោធិនអាជីព គឺជានាយទាហាន នាយទាហានរង ឬបុគ្គលិកសមានកម្ម ដែលត្រូវបាន ទទួលអោយចូលជាយោធិនអាជីព ក្រោយពីបានធ្វើពាក្យសុំចូល ហើយបានតែងតាំង ឋានន្តរសក្តិតាមឋានានុក្រម ។

មាត្រា២៥._យោធិនអាជីព ត្រូវហាមដាច់ខាត :

_មិនអោយយកម៉ោងរដ្ឋបាលទៅប្រកបវិជ្ជាជីវៈជាឯកជន

_មិនអោយយកឥទ្ធិពលនិងអំណាចនៅក្នុងមុខងាររបស់ខ្លួនទៅប្រើ ដើម្បីទាញយកផល ប្រយោជន៍អ្វីមួយឬដើម្បីសំឡុតគំរាមកំហែង បំពានសិទ្ធិពលរដ្ឋ

_មិនអោយប្រកបមុខរបរណាដែលនាំអោយប៉ះពាល់ដល់កិត្តិយស និងសេចក្តីថ្លៃថ្នូរនៃ កងយោធពលខេមរភូមិន្ទ

មាត្រា១៧.– យោធិនត្រូវគោរពនិងអនុវត្តរាល់បញ្ជាដោយមានស្មារតីទទួលខុសត្រូវ ។ បញ្ជាណាដែលមានភាពច្បាស់ក្រឡែតផ្ទុយពីច្បាប់ឬផ្ទុយពីអនុសញ្ញាអន្តរជាតិត្រូវហាមឃាត់ ។ ក្នុងករណីនេះ អ្នកបញ្ជាក្តី អ្នកអនុវត្តក្តី ត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ ។

មាត្រា១៨.– ក្នុងករណីដែលមានពាក្យបណ្តឹងពីតតិយជនចំពោះយោធិន អំពីកំហុសក្នុងការបំរើសេវាដែលមិនមែនជាកំហុសផ្ទាល់ខ្លួនរបស់យោធិន រដ្ឋត្រូវការពារយោធិនរូបនោះ ចំពោះការផ្តន្ទាទោសផ្នែករដ្ឋប្បវេណី ។

យោធិនបំពេញភារកិច្ចដែលមានការគំរាមកំហែងឬវាយប្រហារប្រការណាមួយពីសំណាក់ជនណាម្នាក់ដែលមិនមែនជាកំហុសផ្ទាល់ខ្លួន ត្រូវបានរដ្ឋទទួលការពារ ទទួលសងនូវការខូចខាត និងចេញមុខប្តឹងទៅតុលាការ ។

មាត្រា១៩.– យោធិនដែលជាអ្នកកាន់កាប់គ្រប់គ្រងមូលនិធិ សំភារៈបរិក្ខារឬស្បៀង ហើយធ្វើអោយខូចខាតបាត់បង់ ឬយោធិនណាដែលគ្មានភារកិច្ច ហើយបានបង្កអោយមានការបំផ្លិចបំផ្លាញ ការបាត់បង់ ឬការខូចខាតនូវយោធបរិក្ខារ ឬសំភារៈគ្រឿងបំពាក់ដែលបានប្រគល់អោយ ត្រូវទទួលខុសត្រូវលើសំណង ។ ក្នុងករណីធ្ងន់ធ្ងរ ត្រូវផ្តន្ទាទោសតាមច្បាប់ ។

មាត្រា២០.– យោធិនត្រូវមានកាតព្វកិច្ចរក្សាការសំងាត់ អំពីហេតុការណ៍និងពត៌មានដែលខ្លួនបានដឹងក្នុងពេលបំពេញភារកិច្ច បន្ថែមលើបទប្បញ្ញត្តិនៃច្បាប់ព្រហ្មទណ្ឌ ដែលពាក់ព័ន្ធទៅនឹងការរំលោភលើកាតព្វកិច្ចរក្សាការសំងាត់យោធាឬការសំងាត់ខាងវិជ្ជាជីវៈ ។

ការពង្វាងឬការផ្តល់ពត៌មាន លិខិតស្នាមឬឯកសារនៃសេវាផ្ទុយពីបទបញ្ជាទៅអោយតតិយជនត្រូវហាមឃាត់ ។

ក្រៅពីករណីដែលបានចែងច្បាស់លាស់ក្នុងបទបញ្ជាជាធរមាន យោធិនមិនអាចរួចពីកាតព្វកិច្ចរក្សាការសំងាត់ ឬពីការហាមប្រាមដែលចែងក្នុងកថាខ័ណ្ឌខាងលើទេ លើកលែងតែបានការអនុញ្ញាតពីរដ្ឋមន្ត្រីក្រសួងការពារជាតិ ។

មាត្រា៣១.– ការតម្លើងឋានន្តរសក្តិតាមជំរើសឬតាមអតីតភាពមិនអាចធ្វើបាន បើសិនជាយោធិន មិនបានបំរើគ្រប់រយៈពេលនិងកាន់កាប់មុខនាទីទទួលខុសត្រូវបញ្ជាការដូចកំណត់ខាងក្រោមនេះ :

	រយៈពេលបំរើការងារក្នុងឋានន្តរសក្តិមួយថ្នាក់ដើម្បីអាចតម្លើងបាន	
ឋានន្តរសក្តិ	យោធិនដាក់ឲ្យសំរាប់ប្រើប្រាស់ប្រតិបត្តិការសឹក	យោធិនបំរើក្នុងសេនារដ្ឋបាល
វរសេនីយ៍ឯក វរនាវីឯក	៣ឆ្នាំ	៥ឆ្នាំ
វរសេនីយ៍ទោ វរនាវីទោ	៥ឆ្នាំ	៥ឆ្នាំ
វរសេនីយ៍ត្រី វរនាវីត្រី	៤ឆ្នាំ	៥ឆ្នាំ
អនុសេនីយ៍ឯក អនុនាវីឯក	៦ឆ្នាំ	៦ឆ្នាំ
អនុសេនីយ៍ទោ អនុនាវីទោ	៤ឆ្នាំ	៥ឆ្នាំ
អនុសេនីយ៍ត្រី អនុនាវីត្រី	២ឆ្នាំ	២ឆ្នាំ
នាយចំណង់ នាយនាវីចំណង់	១ឆ្នាំ	១ឆ្នាំ

រយៈពេលសំរាប់តម្លើងឋានន្តរសក្តិអាចខ្លីជាងរយៈពេលដែលកំណត់ខាងលើ ក្នុងកាលៈទេសៈចាំបាច់ដែលកំណត់ដោយអនុក្រឹត្យ ។

_មិនអោយចូលជាសមាជិកនៃក្រុមប្រឹក្សាភិបាលឬគ្រប់គ្រងក្រុមហ៊ុនជាលក្ខណៈឯកជន។

មាត្រា២៦._យោធិនអាជីពត្រូវបានទទួលពិន្ទុមួយឆ្នាំម្តង ។ មេបញ្ជាការផ្ទាល់ជាអ្នកដាក់ពិន្ទុនិងមូលវិចារណ៍ ត្រូវជូនដំណឹងអំពីមូលវិចារណ៍ចំពោះយោធិនអាជីពម្នាក់ៗអោយបានដឹងជារៀងរាល់ឆ្នាំ ។

មាត្រា២៧._យោធិនអាជីពម្នាក់ៗ ត្រូវមានសំណុំឯកសារផ្ទាល់ខ្លួន :

_លិខិតស្នាមទាក់ទងនឹងស្ថានភាពរដ្ឋបាល

_លិខិតស្នាមនិងឯកសារផ្សេងៗដែលទាក់ទងនឹងសេចក្តីសំរេចនិងប្រកាសដែលមានលក្ខណៈស្របតាមលក្ខន្តិកៈ ឬ បទវិន័យ ។

_ព្រឹត្តបត្រពិន្ទុ

ក្នុងសំណុំលិខិតនេះ មិនត្រូវមានឯកសារនិយាយអំពីមតិយោបល់ឬជំនឿក្នុងផ្លូវទស្សនៈវិជ្ជានិងនយោបាយនៃសាមីជនទេ ។

ឯកសារនីមួយៗត្រូវមានលេខរៀង និង ចុះបញ្ជីកា ។

មាត្រា២៨._អាចត្រូវតែងតាំងជានាយទាហានអាជីពបាន ចំពោះជនណាដែល :

_មានសញ្ជាតិខ្មែរ

_មានលិខិតថ្កោលទោសដែលបញ្ជាក់ថាគ្មានទោស

_មានសម្បទាតាមតម្រូវការ ដើម្បីបំពេញមុខងារ ។

មាត្រា២៩._ការជ្រើសរើសនាយទាហានអាជីព ប្រព្រឹត្តទៅតាមការចូលសាលានាយទាហាន ដែលជ្រើសរើសយកបេក្ខជនអោយចូលសិក្សាជាសិស្សនាយទាហាន ដោយការប្រឡងប្រជែងក្នុងចំណោមនិស្សិតនិងដោយការប្រឡងប្រជែងក្នុងចំណោមយោធិន ។

លក្ខខ័ណ្ឌនៃការជ្រើសរើសនេះ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងការពារជាតិ ។

មាត្រា៣០._ការតម្លើងឋានន្តរសក្តិនៃនាយទាហានអាជីពត្រូវគិតទៅតាមរយៈពេលបំរើការងារកន្លងមក ។ នាយទាហានអាជីពទាំងនោះត្រូវមានឈ្មោះក្នុងបញ្ជីអតីតភាព ដែលរៀបចំឡើងតាមលំដាប់សក្តិ និងតាមអង្គរបស់ខ្លួនទៅតាមអតីតភាពនៃនាយទាហានទាំងនោះ ។

-បានចូលបំរើការរយៈពេលយ៉ាងតិច ៤ឆ្នាំ នៅក្នុងកងយោធពលខេមរភូមិន្ទ ហើយមានឋានន្តរសក្តិជានាយទាហានរងស្រាប់

-មានសម្បទាតាមតម្រូវការដើម្បីបំពេញមុខងារ

ការចូលជានាយទាហានរងអាជីពត្រូវសំរេចដោយប្រកាសរបស់ក្រសួងការពារជាតិ។

មាត្រា៣៥.-អតីតភាពនៃនាយទាហានរងអាជីពត្រូវគិតចាប់តាំងពីថ្ងៃចូលបំរើការងារយោធាកន្លងមក ។

មាត្រា៣៦.-ការតម្លើងឋានន្តរសក្តិនាយទាហានរងអាជីព ប្រព្រឹត្តិទៅតាមជំរើស តាមអតីតភាពនិងសមស្របទៅតាមសមាមាត្រ ។ លក្ខខ័ណ្ឌនេះនឹងកំណត់ដោយប្រកាសរបស់ក្រសួងការពារជាតិ ។ ការតម្លើងឋានន្តរសក្តិតាមអតីតភាពនៃនាយទាហានរងអាជីពត្រូវគិតទៅតាមអតីតភាពរបស់សាមីយោធិននៅក្នុងអង្គនីមួយៗ ហើយនិងទៅតាមប្រភេទកងទ័ពឬជំនាញឯកទេស ។

ពុំអាចត្រូវបានតម្លើងឋានន្តរសក្តិបានទេ ក្នុងករណីមិនបានគ្រប់រយៈពេលអប្បបរមាបំរើការងារដូចបង្ហាញក្នុងតារាងខាងក្រោមនេះ :

ឋានន្តរសក្តិ	**រយៈពេលបំរើការក្នុងឋានន្តរសក្តិមួយថ្នាក់ ដើម្បីអាចតម្លើងបាន**	
	យោធិនជាកម្លាំងសំរាប់ប្រើប្រាស់ប្រតិបត្តិការសឹក	**យោធិនបំរើក្នុងសេវារដ្ឋបាល**
ព្រិន្ទបាលឯក នាយចក្របាលឯក	៣ឆ្នាំ	៤ឆ្នាំ
ព្រិន្ទបាលទោ នាយចក្របាលទោ	៣ឆ្នាំ	៤ឆ្នាំ
ពលបាលឯក ចក្របាលឯក	២ឆ្នាំ	៣ឆ្នាំ

ចំពោះនាយទាហានថ្នាក់ឧត្តមសេនីយ៍ ការតម្លើងឋានន្តរសក្តិមិនអាចធ្វើតាមបទប្បញ្ញត្តិខាងលើទេ គឺអាចធ្វើតាមតម្រូវការរបស់កងយោធពលខេមរភូមិន្ទ ។

ចំពោះយោធិនដែលពលី មរណៈក្នុងពេលបេសកកម្ម ត្រូវបានតម្លើងឋានន្តរសក្តិជាកិច្ចបច្ឆាមរណៈ ។

មាត្រា៣២._ការតម្លើងឋានន្តរសក្តិរបស់នាយទាហានអាជីពតាមអតីតភាព ប្រព្រឹត្តឡើងនៅក្នុងអង្គនីមួយៗតាមលំដាប់ថ្នាក់ នៃបញ្ជីអតីតភាព ។

ពុំអាចត្រូវបានតម្លើងឋានន្តរសក្តិតាមជំរើស ក្នុងករណីពុំមានឈ្មោះនៅក្នុងតារាងតម្លើងឋានន្តរសក្តិ ដែលត្រូវរៀបរៀងឡើងក្នុងមួយឆ្នាំម្តង ។

គណៈកម្មការមួយត្រូវបានតែងតាំងឡើងដោយរដ្ឋមន្ត្រីក្រសួងការពារជាតិមានភារកិច្ចរាយការណ៍ជូនរដ្ឋមន្ត្រីនូវមូលវិចារណ៍ចាំបាច់និងពិន្ទុដែលផ្តល់អោយដោយបញ្ជាការតាមជាន់ថ្នាក់របស់សាមីយោធិន ។

ក្នុងករណីដែលមិនអាចជាប់ឈ្មោះនៅក្នុងតារាងតម្លើងឋានន្តរសក្តិប្រចាំឆ្នាំទេ សាមីយោធិនត្រូវបានទទួលសិទ្ធិចុះឈ្មោះមុនគេបង្អស់តាមលេខរៀងនៅក្នុងតារាងតម្លើងឋានន្តរសក្តិឆ្នាំបន្ទាប់ លើកលែងតែគណៈកម្មការសំរេចផ្ទុយពីនេះ ដោយមានសេចក្តីរាយការណ៍សមហេតុផលពីបញ្ជាការគ្រប់គ្រងសាមីយោធិន ។

មាត្រា៣៣._ការតែងតាំងនិងការតម្លើងឋានន្តរសក្តិត្រូវសំរេច :

_ដោយព្រះរាជក្រឹត្យសំរាប់ថ្នាក់ឧត្តមសេនីយ៍ និងឧត្តមនាវី

_ដោយអនុក្រឹត្យសំរាប់នាយទាហានថ្នាក់វរសេនីយ៍និងវរនាវីឯក

_ដោយប្រកាសរបស់ក្រសួងការពារជាតិសំរាប់នាយទាហានចាប់ពីថ្នាក់វរសេនីយ៍ទោ និងវរនាវីទោចុះ ។

មាត្រា៣៤._អាចត្រូវបានតែងតាំងជានាយទាហានរងអាជីព ចំពោះជនណា :

_មានសញ្ជាតិខ្មែរ

_ចូលបំរើតាមកិច្ចសន្យា

មាត្រា៣៧.– គុណប្រយោជន៍នៃនាយទាហានរងអាជីព ត្រូវកំណត់ដោយអនុក្រឹត្យ ។

ជំពូកទី៥

ស្ថានភាពយោធិនអាជីព

មាត្រា៣៨.– យោធិនអាជីពគ្រប់រូប ត្រូវបានដាក់នៅក្នុងស្ថានភាពណាមួយដូចខាងក្រោមនេះ :

១– ស្ថានភាពសកម្មគឺជាស្ថានភាពដែលយោធិនអាជីពកាន់កាប់មុខតំណែងតាមឋានន្តរសក្តិរបស់ខ្លួន ។

២– ស្ថានភាពអសកម្មគឺជាស្ថានភាពបណ្តោះអាសន្នរបស់យោធិនអាជីពដែលមិនអាចកាន់កាប់មុខតំណែងតាមឋានន្តរសក្តិរបស់ខ្លួន ក្នុងរយៈពេលលើសពី ៦ខែ ឡើងទៅ ដោយសារហេតុផលផ្សេងៗ ។

៣– ស្ថានភាពក្រៅតំណែងគឺជាស្ថានភាពរបស់យោធិនអាជីពដែលត្រូវបានដាក់មួយរយៈអោយនៅក្រៅអង្គដើមរបស់ខ្លួន ដើម្បីបំពេញមុខងារសាធារណៈណាមួយផ្សេងក្នុងរដ្ឋបាលស៊ីវិលឬមុខងារឯកជនណាមួយផ្សេងដែលជាផលប្រយោជន៍សាធារណៈ ។

៤– ស្ថានភាពចូលនិវត្តន៍គឺជាស្ថានភាពរបស់យោធិនអាជីពដែលមានអាយុត្រូវចូលនិវត្តន៍ ស្របតាមបទប្បញ្ញត្តិនៃច្បាប់ស្ត... [illegible]សោធននិវត្តន៍និងសោធនបាត់បង់សមត្ថភាពការងារចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ ។

៥– ស្ថានភាពក្រៅក្របខ័ណ្ឌគឺជាស្ថានភាពរបស់យោធិនអាជីពដែលអាចដល់កំណត់ពេលចូលនិវត្តន៍បាន អនុលោមតាមចំណុច ៤នៃមាត្រានេះ តែត្រូវបានអនុញ្ញាតអោយបំរើការងារបន្តទៀតនៅក្នុងសេវា ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់កងយោធពលខេមរភូមិន្ទ និង សំណូមពរសាមីយោធិនផង ។

មាត្រា៣៩.– បែបបទនៃការទទួលសិទ្ធិនិងកាតព្វកិច្ចទាក់ទងនឹងស្ថានភាពដែលមានចែងក្នុងចំណុច ១.២.៣.៤.៥.នៃមាត្រា ៣៨ ព្រមទាំងបទប្បញ្ញត្តិដោយឡែកចំពោះនាយទាហាន ថ្នាក់ឧត្តមសេនីយ៍ ត្រូវកំណត់ដោយអនុក្រឹត្យ ។

មាត្រា៤០._ភាពយោធានិងបាត់បង់ ក្នុងករណីដែលយោធិនបានសុំលាលែងពីជួរទ័ព ដោយមានការព្រមព្រៀងពីអាជ្ញាធរសមត្ថកិច្ច ឬក្នុងករណីដែលយោធិនបានចូលក្នុងក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិល ឬក្នុងករណីដែលយោធិនបានបាត់បង់ឋានន្តរសក្តិតាមសាលក្រមតុលាការ ។

យោធិនដែលបានបញ្ចប់ភាពយោធាដូចបានចែងក្នុងចំណុច ៤ នៃមាត្រា ៣៨ ត្រូវបញ្ចូលទៅក្នុងក្របខ័ណ្ឌយោធាបំរុង ហើយរក្សាឋានន្តរសក្តិដែលសាមីយោធិនមានស្រាប់ ។

ចំពោះយោធិនដែលតុលាការបានផ្តន្ទាទោស មិនត្រូវបញ្ចូលទៅក្នុងក្របខ័ណ្ឌយោធាបំរុងបានទេ ។

ជំពូកទី៦

យោធិនជាប់កិច្ចសន្យា

មាត្រា៤១._យោធិនជាប់កិច្ចសន្យាគឺជាអ្នកចូលបំរើការងារដោយស្ម័គ្រចិត្តតាមកិច្ចសន្យា នៅក្នុងឋានន្តរសក្តិជាពលទាហាន និងជានាយទាហានរង នៅក្នុងកងយោធពលខេមរភូមិន្ទសំរាប់ :

_មួយរយៈពេលដែលបានកំណត់

_ពេលមានសង្គ្រាមទាំងមូលឬមួយរយៈ

ចំនួននិងល័ក្ខខ័ណ្ឌនៃការជ្រើសរើស ត្រូវកំណត់ដោយអនុក្រឹត្យ ។

មាត្រា៤២._យោធិនជាប់កិច្ចសន្យាត្រូវបានជ្រើសរើសចំពោះជនណាដែល :

_មានសញ្ជាតិខ្មែរ លើកលែងតែក្នុងពេលមានសង្គ្រាម

_មានអាយុគ្រប់ ១៨ ឆ្នាំ

_មានសម្បទាតាមតម្រូវការដើម្បីបំពេញមុខងារ ។

មាត្រា៤៣._ចំពោះយោធិនជាប់កិច្ចសន្យាអាចសុំបន្តកិច្ចសន្យាបាន ចាប់ពីថ្ងៃចប់កិច្ចសន្យាមុន ។

មាត្រា៤៤._ឋានន្តរសក្តិ ស្ថានភាពបាត់បង់សុខភាព សមត្ថភាពការងារ ការហ្វឹកហ្វឺនវិជ្ជាជីវៈ ព្រមទាំងគុណប្រយោជន៍ចំពោះយោធិនជាប់កិច្ចសន្យា ត្រូវកំណត់ដោយអនុក្រឹត្យ ។

ជំពូកទី ៧

ទណ្ឌកម្ម

មាត្រា៤៥._យោធិន ក្នុងករណីមានកំហុសត្រូវទទួលទណ្ឌកម្មយោធាដោយមិនគិតពីការផ្តន្ទាទោសតាមផ្លូវតុលាការ :

១_ទណ្ឌកម្មខាងផ្នែកវិន័យ ដែលកំណត់ដោយបទវិន័យទូទៅ ក្នុងកងយោធពលខេមរភូមិន្ទ ។

២_ទណ្ឌកម្មតាមលក្ខន្តិកៈទូទៅដែលមានរៀបរាប់នៅក្នុងមាត្រា៤៨.៤៩.៥០.៥១ នៃច្បាប់នេះ ។

មាត្រា៤៦._មុននឹងដាក់ទណ្ឌកម្មតាមលក្ខន្តិកៈទូទៅ ត្រូវសុំយោបល់ក្រុមប្រឹក្សាវិន័យជាមុនសិន ។ ការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាវិន័យត្រូវកំណត់ដោយប្រកាសរបស់ក្រសួងការពារជាតិ ។

មាត្រា៤៧._ក្រោយពីបានទទួលយោបល់ពីក្រុមប្រឹក្សាវិន័យ រដ្ឋមន្ត្រីក្រសួងការពារជាតិ ឬអាជ្ញាធរមានសមត្ថកិច្ចក្នុងរឿងនេះ អាចសំរេចដាក់ទណ្ឌកម្មដែលមានចែងក្នុងមាត្រា៤៥ នៃច្បាប់នេះ ។

ការដាក់ទណ្ឌកម្មខាងផ្នែកវិន័យនិងទណ្ឌកម្មតាមលក្ខន្តិកៈទូទៅ អាចសំរេចដាក់ទាំងពីរបាន ។

មាត្រា៤៨._ទណ្ឌកម្មតាមលក្ខន្តិកៈទូទៅអនុវត្តចំពោះយោធិនអាជីពមាន :

_ការលុបឈ្មោះចេញពីតារាងតម្លើងឋានន្តរសក្តិ

_ការដកហូតមុខតំណែង ដោយដាក់អោយនៅក្នុងស្ថានភាពអសកម្ម

_ការលុបឈ្មោះចេញពីក្របខ័ណ្ឌ

_ការព្យួរមុខតំណែង

មាត្រា៤៩.– ការដកហូតមុខតំណែងដោយដាក់អោយនៅក្នុងស្ថានភាពអសកម្មតាមបទប្បញ្ញត្តិក្នុងចំណុច ២ នៃមាត្រា ៣៨ ត្រូវអនុវត្តចំពោះតែយោធិនដែលមិនមានសិទ្ធិចូលនិវត្តន៍ភ្លាមៗ ។ ការដកហូតមុខតំណែងមិនអាចមានរយៈពេលលើសពី៣ ឆ្នាំឡើយ ។

នៅពេលផុតកំណត់នៃរយៈពេលដែលស្ថិតនៅក្នុងស្ថានភាពអសកម្ម យោធិនត្រូវដាក់អោយនៅក្នុងស្ថានភាពសកម្មវិញ ។

រយៈពេលអសកម្មដោយការដកហូតតំណែង មិនត្រូវយកមកគិតក្នុងការតម្លើងឋានន្តរសក្តិនិងសំរាប់ចូលនិវត្តន៍ទេ ។ នៅក្នុងស្ថានភាពនេះ យោធិនលែងមានឈ្មោះនៅក្នុងបញ្ជីអតីតភាព ហើយមានសិទ្ធិទទួលតែ ៤៥% (សែសិបប្រាំភាគរយ) នៃប្រាក់បៀវត្សឋានន្តរសក្តិ ។

មាត្រា៥០.– ការលុបឈ្មោះយោធិនអាជីពចេញពីក្របខ័ណ្ឌអាចអនុវត្តបាន ដោយមិនគិតពីរយៈពេលដែលបានបំរើការងារ ។

មាត្រា៥១.– ក្នុងករណីមានកំហុសធ្ងន់ធ្ងរដែលប្រព្រឹត្តិឡើងដោយយោធិនអាជីព យោធិនរូបនោះអាចត្រូវព្យួរមុខតំណែងជាបន្ទាន់ដោយអាជ្ញាធរមានសមត្ថកិច្ចដាក់វិន័យ ។

ក្នុងករណីខាងលើនេះ រដ្ឋមន្ត្រីក្រសួងការពារជាតិមានសិទ្ធិកំណត់ចំនួនប្រាក់សញ្ញ័យដែលត្រូវកាត់ទុក ។ ប្រាក់សញ្ជ័យនេះមិនត្រូវលើសពីពាក់កណ្តាលនៃប្រាក់បៀវត្ស ឋានន្តរសក្តិរបស់សាមីយោធិនឡើយ ។

ស្ថានភាពដែលយោធិនព្យួរមុខតំណែង ត្រូវតែដោះស្រាយជាស្ថាពរនៅក្នុងរយៈពេល ៤ខែ គិតពីថ្ងៃដែលសេចក្តីសំរេចព្យួរមុខតំណែងចូលជាធរមាន ។ កាលណាពុំមានសេចក្តីសំរេចណាមួយត្រូវធ្វើឡើងនៅពេលបញ្ចប់រយៈពេលនេះ សាមីយោធិនត្រូវបានទទួលសាជាថ្មីនូវបៀវត្សគ្រប់ចំនួន លើកលែងតែយោធិននោះជាកម្មវត្ថុនៃបណ្តឹងអាជ្ញា ។

ក្នុងករណីយោធិនដែលត្រូវព្យួរមុខតំណែងមិនទទួលរងនូវទណ្ឌកម្មណាមួយតាមលក្ខន្តិកៈទូទៅ ឬបើនៅពេលបញ្ចប់ក្នុងរយៈពេលដូចមានចែងក្នុងកថាខ័ណ្ឌខាងលើ

ហើយបើគ្មានសេចក្តីសំរេចណាមួយចំពោះយោធិនរូបនេះទេ យោធិននោះមានសិទ្ធិទាមទារយកសំណងប្រាក់សញ្ជ័យដែលបានកាត់យកពីបៀវត្សរបស់ខ្លួន ។

ក្នុងករណីនៃបទឧក្រិដ្ឋអាជ្ញា សិទ្ធិទទួលបៀវត្សត្រូវបានបញ្ឈប់តែនៅក្រោយពេលដែលមានសាលក្រមរបស់សាលាជំរះក្តីត្រូវបានចាត់ទុកជាស្ថាពរ ។

ជំពូកទី៨

អវសានប្បញ្ញត្តិ

មាត្រា៥២._ បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧
ក្នុងព្រះបរមនាម និងតាមព្រះរាជគ្រាស់បង្គាប់
ប្រមុខរដ្ឋស្តីទី
ហត្ថលេខា
ជា ស៊ីម

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ
នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២
ហត្ថលេខា
អ៊ឹង ហួត ហ៊ុន សែន

បានជំរាបជូន
ឯកឧត្តមនាយករដ្ឋមន្ត្រីទី១ និង
សម្តេចនាយករដ្ឋមន្ត្រីទី២
សហរដ្ឋមន្ត្រីក្រសួងការពារជាតិ
ហត្ថលេខា
ទៀ បាញ់ នា ចឹរ៉ាត់

ព្រះរាជក្រម ជស/រកត/១១៩៧/០៦

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ រាជហរិវង្ស
ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម
ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
ព្រះចៅក្រុងកម្ពុជាធិបតី

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស-៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៩០ ចុះថ្ងៃទី ៣១ ខែតុលា ឆ្នាំ១៩៩៤ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៨៩៧/១៤៧ ចុះថ្ងៃទី ០៧ ខែសីហា ឆ្នាំ ១៩៩៧ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតក្រសួងសុខាភិបាល
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំ អំពីឯកឧត្តមនាយករដ្ឋមន្ត្រីទី១និងសម្តេចនាយករដ្ឋមន្ត្រីទី២ និងអំពីរដ្ឋមន្ត្រីក្រសួងសុខាភិបាល

ប្រកាសអោយប្រើ

ច្បាប់ស្តីពីការរំលូតកូន ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ០៦ ខែតុលា ឆ្នាំ១៩៩៧ នាសម័យប្រជុំលើកទី៨ នីតិកាលទី១ ដែលមានសេចក្តីទាំងស្រុងដូចតទៅ :

ច្បាប់

ស្តីពីការរំលូតកូន

ជំពូកទី ១

បទប្បញ្ញត្តិទូទៅ

មាត្រា១.– ច្បាប់នេះមានគោលដៅកំណត់ពីបែបបទ និងល័ក្ខខ័ណ្ឌនៃការរំលូតកូន ។

មាត្រា២.– ការរំលូតកូនគឺជាការបញ្ចប់គភ៌តាមវិធីវេជ្ជសាស្រ្ត ឬតាមវិធីណាមួយ ។

មាត្រា៣.– ស្រ្តីមានគភ៌ទាំងឡាយអាចសុំអោយគ្រូពេទ្យធ្វើការរំលូតកូនបាន ក្រោយពីបានបំពេញល័ក្ខខ័ណ្ឌដូចមានចែងក្នុងមាត្រា ៨ នៃច្បាប់នេះ ។

មាត្រា៤.– ក្នុងករណីណាក៏ដោយ ការរំលូតកូនត្រូវតែមានសំណូមពរនិងបានទទួលការយល់ព្រមពីស្រ្តីដែលមានគភ៌ ។

មាត្រា៥.– មានតែវេជ្ជបណ្ឌិត ឬគ្រូពេទ្យមធ្យម ឬឆ្មបមធ្យមដែលបានទទួលការអនុញ្ញាតពីក្រសួងសុខាភិបាល ទើបអាចធ្វើការរំលូតកូនបាន ។

ជំពូកទី

បែបបទ និងល័ក្ខខ័ណ្ឌ

មាត្រា៦.– ការរំលូតកូនប្រព្រឹត្តទៅបានតែនៅក្នុងមន្ទីរពេទ្យ មណ្ឌលសុខភាព គ្លីនិក មន្ទីរសម្ភពសាធារណៈ ឬឯកជនដែលបានទទួលការអនុញ្ញាតពីក្រសួងសុខាភិបាល ។ រាល់សេវាដែលក្រសួងសុខាភិបាលបានអនុញ្ញាតអោយជាកន្លែងធ្វើការរំលូតកូនត្រូវមាន :

– លទ្ធភាពបច្ចេកទេសព្យាបាលបន្ទាន់នូវរាល់ផលវិបាកនៃការរំលូតកូន

– មធ្យោបាយបញ្ជូនទៅមន្ទីរពេទ្យ ប្រសិនបើមានការចាំបាច់

មាត្រា៧.– វេជ្ជបណ្ឌិត ឬគ្រូពេទ្យមធ្យម ឬឆ្មបមធ្យមដែលមានភារកិច្ចធ្វើការរំលូតកូន ត្រូវពន្យល់ណែនាំដល់ស្ត្រីដែលមានគភ៌មកសុំធ្វើការរំលូតកូន គឺគ្រោះថ្នាក់ដែលអាចកើតមានឡើង

ជាយថាហេតុបណ្តាលមកពីការរំលូតកូននេះនិងពីផលប្រយោជន៍នៃកិច្ចពន្យារកំណើត។

ប្រសិនបើស្ត្រីដែលមានគភ៌នោះ នៅតែទទូចសុំធ្វើការរំលូតកូន វេជ្ជបណ្ឌិតឬគ្រូពេទ្យមធ្យមឬឆ្មបមធ្យមអាចធ្វើការរំលូតកូនបាន តែត្រូវស្ថិតក្នុងលក្ខខ័ណ្ឌដូចមានចែងក្នុងមាត្រា ៨ នៃច្បាប់នេះ ។

មាត្រា៨.– ការរំលូតកូនអាចធ្វើទៅបានចំពោះតែគភ៌ណាដែលមានអាយុតិចជាង ១២ សប្តាហ៍ ។ លើសពី ១២ សប្តាហ៍នៃអាយុគភ៌ ការរំលូតកូនអាចទទួលការអនុញ្ញាតបាន លុះតែក្នុងពេលធ្វើរោគវិនិច្ឆ័យឃើញថា :

–គភ៌នោះមានភវនីយភាពមិនលូតលាស់ដូចប្រក្រតី ឬបង្កគ្រោះថ្នាក់ដល់ជីវិតម្តាយ

–កូនដែលនឹងកើតមកអាចជម្ងឺធ្ងន់ធ្ងរព្យាបាលពុំជា

–ក្នុងករណីដែលត្រូវគេរំលោភបណ្តាលអោយមានគភ៌ ការរំលូតកូនអាចប្រព្រឹត្តទៅបានដោយមានគិតពីលក្ខខ័ណ្ឌដូចមានចែងខាងលើ តែត្រូវមានការស្នើសុំពីសាមីខ្លួន បើស្ត្រីនោះមានអាយុ ១៨ ឆ្នាំឡើងទៅ ឬការស្នើសុំដោយទទូចពីឪពុកម្តាយ ឬ អាណាព្យាបាល និងសាមីខ្លួន បើស្ត្រីដែលមានគភ៌មានអាយុតិចជាង ១៨ឆ្នាំ ។

ការសំរេចនៃបញ្ហានេះ ត្រូវមានការឯកភាពពីក្រុមគ្រូសារ ២ ឬ ៣រូប រួមទាំងសាមីខ្លួនផង ។ លក្ខខ័ណ្ឌបច្ចេកទេសសម្រាប់ការអនុវត្តន៍នៃមាត្រានេះ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងសុខាភិបាល ។

មាត្រា៩.– រាល់ឯកសារដែលមានទាក់ទងទៅនឹងការរំលូតកូន ត្រូវរក្សាទុកជាការសម្ងាត់ ហើយអាចផ្តល់ទៅសាមីខ្លួន ឬតុលាការប្រសិនបើមានការស្នើសុំជាលាយលក្ខអក្សរ ។

មាត្រា១០.– សេវាដែលក្រសួងសុខាភិបាលបានអនុញ្ញាតអោយជាកន្លែងធ្វើការរំលូតកូនដូចមានចែងនៅក្នុងមាត្រា ៦ នៃច្បាប់នេះ ត្រូវរៀបចំឯកសារច្បាស់លាស់ ស្តីពីករណីរំលូតកូននីមួយៗ ហើយត្រូវធ្វើរបាយការណ៍ប្រចាំខែមកក្រសួងសុខាភិបាលដោយឡែងទាត់នូវចំនួនរំលូតកូន និងមធ្យោបាយរំលូត ។

ជំពូកទី ៣

សមត្ថកិច្ចត្រួតពិនិត្យ

មាត្រា១១.–ការត្រួតពិនិត្យការរំលូតកូនតាមការកំណត់នៃច្បាប់នេះ ជាសមត្ថកិច្ចរបស់ក្រសួងសុខាភិបាល ។

ជំពូកទី ៤

ទោសប្បញ្ញត្តិ

មាត្រា១២.–ជនទាំងឡាយណាដែលបានប្រព្រឹត្តល្មើសនឹងមាត្រា ៥ ឬ ៦ នៃច្បាប់នេះ ត្រូវទទួលទណ្ឌកម្ម និងទោសទណ្ឌដូចខាងក្រោម :

–បើជាវេជ្ជបណ្ឌិតឬគ្រូពេទ្យមធ្យមឬជាឆ្មបមធ្យមត្រូវព្រមាន ។ ក្នុងករណីមិនរាងចាលត្រូវបញ្ឈប់ពីមុខងារឬបិទគ្លីនិកឬមន្ទីរសម្ភពនោះ ដោយមិនទាន់គិតដល់បទល្មើសព្រហ្មទណ្ឌដូចចែងខាងក្រោមនេះ ។

–បើមិនមែនជាវេជ្ជបណ្ឌិតឬគ្រូពេទ្យមធ្យមឬជាឆ្មបមធ្យមត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ ខែ ទៅ ១ឆ្នាំ ។

–បើការរំលូតកូននោះបណ្តាលអោយស្ត្រីដែលមានគភ៌មានជម្ងឺរ៉ាំរ៉ៃឬពិការ ត្រូវផ្តន្ទាទោសពី ១ឆ្នាំ ទៅ ៥ឆ្នាំ ។

–បើការរំលូតកូនបណ្តាលអោយស្ត្រីដែលមានគភ៌មានគ្រោះថ្នាក់ដល់ស្លាប់ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ឆ្នាំ ទៅ ១០ឆ្នាំ ។

មាត្រា១៣.–វេជ្ជបណ្ឌិត ឬគ្រូពេទ្យមធ្យម ឬឆ្មបមធ្យមដែលបានទទួលការអនុញ្ញាតអោយធ្វើការរំលូតកូន ហើយមិនគោរពលក្ខខណ្ឌណាមួយដូចចែងក្នុងមាត្រា ៨ នៃច្បាប់នេះ ត្រូវដកហូតយកលិខិតអនុញ្ញាតដែលចេញអោយដោយក្រសួងសុខាភិបាល ដោយមិនទាន់គិតដល់បទល្មើសព្រហ្មទណ្ឌដែលមានចែងក្នុងមាត្រា ១២ នៃច្បាប់នេះ ។

លើកលែងតែក្នុងករណីធ្ងន់ធ្ងរដែលស្ត្រីមានគភ៌ត្រូវសង្គ្រោះបន្ទាន់ វិធីវេជ្ជសាស្ត្រនឹងត្រូវបានធានាចំពោះមុខច្បាប់ ។

មាត្រា១៤._ជនទាំងឡាយណា ដែលបង្ខិតបង្ខំអោយស្ត្រីដែលមានគភ៌ធ្វើការរំលូតកូន ឬធ្វើអោយរលូតកូនដោយចេតនា ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ឆ្នាំ ទៅ ៥ឆ្នាំ ។ បើការបង្ខិតបង្ខំអោយស្ត្រីដែលមានគភ៌ធ្វើការរំលូតកូន ឬធ្វើអោយរលូតកូនដោយចេតនានោះ បណ្តាលអោយស្ត្រីដែលមានគភ៌មានជម្ងឺពិការ ឬបណ្តាលអោយស្លាប់ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ពី ៥ឆ្នាំ ទៅ ១០ឆ្នាំ ។

មាត្រា១៥._ជនណាដែលប្រព្រឹត្តល្មើសនឹងមាត្រា ៩ នៃច្បាប់នេះ ត្រូវទទួលទណ្ឌកម្មដូចតទៅ :

_បើជាមន្ត្រីរាជការ ត្រូវទទួលទណ្ឌកម្មតាមមាត្រា ៤០ និង ៤១ នៃច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល ។

_បើមិនមែនជាមន្ត្រីរាជការ ត្រូវបិទគ្លីនិក ឬមន្ទីរសម្ភពឯកជនពី ១ខែ ទៅ ៣ខែ ឬពិន័យជាប្រាក់ពី ប្រាំលានរៀល (៥.០០០.០០០) ដល់ដប់លានរៀល (១០.០០០.០០០) ។

ជំពូកទី ៥

អវសានប្បញ្ញត្តិ

មាត្រា១៦._បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១២ ខែវិច្ឆិកា ឆ្នាំ១៩៩៧

ក្នុងព្រះបរមនាម និងតាមព្រះរាជបញ្ជាសបង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

ជា ស៊ីម

បានជំរាបជូន

ឯកឧត្តមនាយករដ្ឋមន្ត្រីទី១ និង

សម្តេច នាយករដ្ឋមន្ត្រីទី២

រដ្ឋមន្ត្រីក្រសួងសុខាភិបាល

ហត្ថលេខា

ឈា ថាំង

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

ហត្ថលេខា

អ៊ឹង ហួត ហ៊ុន សែន

២_ព្រះរាជក្រឹត្យ

ព្រះរាជក្រឹត្យ ជស/រកត/១១៩៧/២២៣

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ រាជហរិវង្ស

ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤
- យោងតាមសំណើរបស់ប្រមុខរាជរដ្ឋាភិបាល ចុះថ្ងៃទី ២៨ ខែតុលា ឆ្នាំ១៩៩៧

ត្រាស់បង្គាប់

មាត្រា១._តែងតាំងលោក **អ៊ាន ឈីមេង** ជាទីប្រឹក្សាផ្ទាល់ឯកឧត្តមនាយករដ្ឋមន្ត្រីទី១ នៃរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកផ្នែករដ្ឋបាល និងកិច្ចការព្រំដែន ដោយមានឋានៈស្មើអនុរដ្ឋលេខាធិការ ។

មាត្រា២._នាយករដ្ឋមន្ត្រីទី១ និងនាយករដ្ឋមន្ត្រីទី២ នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ អោយបានសំរេច ។

មាត្រា៣.– ព្រះរាជក្រឹត្យនេះ ចូលជាធរមានច្បាប់ ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧

ក្នុងព្រះបរមនាម និងតាមព្រះរាជបញ្ជាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

ជា ស៊ីម

* * *

ព្រះរាជក្រឹត្យ ជស/រកត/១១៩៧/២២៥

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ រាជហរិវង្ស

ឧភតោសុជាត ពិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

– បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣

– បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

– បានឃើញច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី១៩ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤

– យោងតាមសំណើរបស់ប្រមុខរាជរដ្ឋាភិបាល ចុះថ្ងៃទី ២៨ ខែតុលា ឆ្នាំ១៩៩៧

ត្រាស់បង្គាប់

មាត្រា១.– តែងតាំងឯកឧត្តម **នី** **តេនា** ជាទីប្រឹក្សាផ្ទាល់ឯកឧត្តមនាយករដ្ឋមន្ត្រីទី១ នៃរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកផ្នែក ឧស្សាហកម្ម រ៉ែ និងថាមពល ដោយមានឋានៈស្មើអនុរដ្ឋលេខាធិការ ។

មាត្រា២.–នាយករដ្ឋមន្ត្រីទី១ និងនាយករដ្ឋមន្ត្រីទី២ នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត ... បានសំរេច ។

មាត្រា៣.–ព្រះរាជក្រឹត្យនេះ ចូលជាធរមានច្បាប់ ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧

ក្នុងព្រះបរមនាម និងតាមព្រះរាជក្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

ជា ស៊ីម

* * *

ព្រះរាជក្រឹត្យ ជស/រកត/១១៩៧/២២៦

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ រាជហរិវង្ស

ឧភតោសុជាត ពិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

–បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣

–បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

–បានឃើញច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤

–យោងតាមសំណើរបស់ប្រមុខរាជរដ្ឋាភិបាល ចុះថ្ងៃទី ២៨ ខែតុលា ឆ្នាំ១៩៩៧

ត្រាស់បង្គាប់

មាត្រា១._ តែងតាំងឯកឧត្តម **ប្រាក់ ខិន** ជាទីប្រឹក្សាផ្ទាល់ឯកឧត្តមនាយករដ្ឋមន្ត្រីទី១ នៃរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកផ្នែករដ្ឋបាល ដោយមានឋានៈស្មើអនុរដ្ឋលេខាធិការ ។

មាត្រា២._ នាយករដ្ឋមន្ត្រីទី១ និងនាយករដ្ឋមន្ត្រីទី២ នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ អោយបានសំរេច ។

មាត្រា៣._ ព្រះរាជក្រឹត្យនេះ ចូលជាធរមានច្បាប់ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧

ក្នុងព្រះបរមនាម និងតាមព្រះរាជក្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

ជា ស៊ីម

* * *

ព្រះរាជក្រឹត្យ ជស/រកត/១១៩៧/២២៧

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ រាជហរិវង្ស

ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

_បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣

_បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

–បានឃើញ[illegible]ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ១៩[illegible]បអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤

–យោងតាម[illegible]ការីរបស់ប្រមុខរាជរដ្ឋាភិបាល ចុះថ្ងៃទី ២៨ ខែតុលា ឆ្នាំ១៩៩៧

ត្រាសបង្គាប់

មាត្រា១.–តែង[illegible] **អ៊ាចហ្វ** ជាទីប្រឹក្សាផ្ទាល់ឯកឧត្តមនាយករដ្ឋមន្ត្រីទី១ នៃរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកផ្នែកសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដោយមានឋានៈស្មើរដ្ឋលេខាធិការ។

មាត្រា២.–នាយករដ្ឋមន្ត្រីទី១ និងនាយករដ្ឋមន្ត្រីទី២ នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ អោយបានសំរេច ។

មាត្រា៣.–ព្រះរាជក្រឹត្យនេះ ចូលជាធរមានច្បាប់ ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧

ក្នុងព្រះបរមនាម និងតាមព្រះរាជក្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

ជា ស៊ីម

* * *

ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៧/២២៨

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ រាជហរិវង្ស

ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

–បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣

–បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

– បានឃើញច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី១៩ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤

– យោងតាមសំណើរបស់ប្រមុខរាជរដ្ឋាភិបាល ចុះថ្ងៃទី ២៨ ខែតុលា ឆ្នាំ១៩៩៧

ត្រាស់បង្គាប់

មាត្រា១.– តែងតាំងឯកឧត្ដមបណ្ឌិត **សុខ ម៉ារឿន** ជាទីប្រឹក្សាផ្ទាល់ឯកឧត្ដមនាយករដ្ឋមន្ត្រីទី១ នៃរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកផ្នែកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយមានឋានៈស្មើរដ្ឋលេខាធិការ ។

មាត្រា២.– នាយករដ្ឋមន្ត្រីទី១ និងនាយករដ្ឋមន្ត្រីទី២ នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ អោយបានសំរេច ។

មាត្រា៣.– ព្រះរាជក្រឹត្យនេះ ចូលជាធរមានច្បាប់ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្ដីទី

ហត្ថលេខា

ជា ស៊ីម

* * *

ព្រះរាជក្រឹត្យ ជស/រកត/១១៩៧/២២៩

យើង

ព្រះបាទសម្ដេចព្រះ នរោត្តម សីហនុ រាជហរិវង្ស

ឧភតោសុជាត ចិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

– បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣

–បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

–បានឃើញច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤

–យោងតាមសំណើរបស់ប្រមុខរាជរដ្ឋាភិបាល ចុះថ្ងៃទី ២៨ ខែតុលា ឆ្នាំ១៩៩៧

ត្រាស់បង្គាប់

មាត្រា១.–តែងតាំងឯកឧត្តម **ឌុយ សារិនដេត** ជាទីប្រឹក្សាផ្ទាល់ឯកឧត្តមនាយករដ្ឋមន្ត្រីទី១ នៃរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកផ្នែកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយមានឋានៈស្មើរដ្ឋលេខាធិការ ។

មាត្រា២.–នាយករដ្ឋមន្ត្រីទី១ និងនាយករដ្ឋមន្ត្រីទី២ នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ អោយបានសំរេច ។

មាត្រា៣.–ព្រះរាជក្រឹត្យនេះ ចូលជាធរមានច្បាប់ ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

ជា ស៊ីម

* * *

ព្រះរាជក្រឹត្យ ជស/រកត/១១៩៧/២៣០

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ រាជហរិវង្ស

ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

–បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣

-បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤

-យោងតាមសំណើរបស់ប្រមុខរាជរដ្ឋាភិបាល ចុះថ្ងៃទី ២៨ ខែតុលា ឆ្នាំ១៩៩៧

ត្រាស់បង្គាប់

មាត្រា១.-តែងតាំងឯកឧត្តម **ជ័យ ឥន្ទកេរ្តិ៍** ជាទីប្រឹក្សាផ្ទាល់ឯកឧត្តមនាយករដ្ឋមន្ត្រីទី១ នៃរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកផ្នែកច្បាប់ ដោយមានឋានៈស្មើរដ្ឋលេខាធិការ ។

មាត្រា២.-នាយករដ្ឋមន្ត្រីទី១ និងនាយករដ្ឋមន្ត្រីទី២ នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ អោយបានសំរេច ។

មាត្រា៣.-ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

ជា ស៊ីម

• • •

ព្រះរាជក្រឹត្យ ជស/រកត/១១៩៧/២៣១

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ រាជហរិវង្ស

ឧភតោសុជាត ចិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣

_បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

_បានឃើញច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤

_យោងតាមសំណើរបស់ប្រមុខរាជរដ្ឋាភិបាល ចុះថ្ងៃទី ២៨ ខែតុលា ឆ្នាំ១៩៩៧

ត្រាស់បង្គាប់

មាត្រា ១._តែងតាំងឯកឧត្តម **ខេង ម៉េងស៊ាន** ជាទីប្រឹក្សាផ្ទាល់ឯកឧត្តមនាយករដ្ឋមន្ត្រីទី១ នៃ រាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកផ្នែកគណនេយ្យ និងគ្រប់គ្រងដោយមានឋានៈស្មើរដ្ឋលេខាធិការ ។

មាត្រា២._នាយករដ្ឋមន្ត្រីទី១ និងនាយករដ្ឋមន្ត្រីទី២ នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ អោយបានសំរេច ។

មាត្រា ៣._ព្រះរាជក្រឹត្យនេះ ចូលជាធរមានច្បាប់ ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

ជា ស៊ីម

* * *

ព្រះរាជក្រឹត្យ ជស/រកត/១១៩៧/២៣២

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ រាជាវរ័នឲ្យ

ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

_បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣

-បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤

-យោងតាមសំណើរបស់ប្រមុខរាជរដ្ឋាភិបាល ចុះថ្ងៃទី ២៨ ខែតុលា ឆ្នាំ១៩៩៧

ត្រាស់បង្គាប់

មាត្រា១.-តែងតាំងឯកឧត្តមបណ្ឌិត **ឡុង សៀម** ជាទីប្រឹក្សាផ្ទាល់ឯកឧត្តមនាយករដ្ឋមន្ត្រីទី១ នៃរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកផ្នែកវប្បធម៌ និង អក្សរសាស្ត្រខ្មែរ ដោយមានឋានៈស្មើរដ្ឋលេខាធិការ ។

មាត្រា២.-នាយករដ្ឋមន្ត្រីទី១ និងនាយករដ្ឋមន្ត្រីទី២ នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ អោយបានសំរេច ។

មាត្រា៣.-ព្រះរាជក្រឹត្យនេះ ចូលជាធរមានច្បាប់ ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧
ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

ជា ស៊ីម

ព្រះរាជក្រឹត្យ ជស/រកត/១១៩៧/២៣៣

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ រាជហរិវង្ស

ឧភតោសុជាត ធិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤
- យោងតាមសំណើរបស់ប្រមុខរាជរដ្ឋាភិបាល ចុះថ្ងៃទី ២៨ ខែតុលា ឆ្នាំ១៩៩៧

ព្រះរាជក្រឹត្យ

ប្រកាសបង្គាប់

មាត្រា១.– តែងតាំងឯកឧត្តម **សំ យក្ខ័អ៊ីមឱឡឡា** ជាទីប្រឹក្សាផ្ទាល់ឯកឧត្តមនាយករដ្ឋមន្ត្រីទី១ នៃរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកផ្នែកសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដោយមានឋានៈស្មើរដ្ឋលេខាធិការ ។

មាត្រា២.– នាយករដ្ឋមន្ត្រីទី១ និងនាយករដ្ឋមន្ត្រីទី២ នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ អោយបានសំរេច ។

មាត្រា៣.– ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧

ក្នុងព្រះបរមនាម និងតាមព្រះរាជក្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

ជា ស៊ីម

ព្រះរាជក្រឹត្យ នស/រកត/១១៩៧/២៣៤

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ រាជហរិវង្ស

ឧភតោសុជាត ពិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤
- យោងតាមសំណើរបស់ប្រមុខរាជរដ្ឋាភិបាល ចុះថ្ងៃទី ២៨ ខែតុលា ឆ្នាំ១៩៩៧

ត្រាស់បង្គាប់

មាត្រា១.– តែងតាំងឯកឧត្តម **ហៀក ម៉េងហួរ** ជាទីប្រឹក្សាផ្ទាល់ឯកឧត្តមនាយករដ្ឋមន្ត្រីទី១ នៃរាជរដ្ឋាភិបាលកម្ពុជា បន្ថែមលើមុខងារបច្ចុប្បន្ន ជានាយកខុទ្ទកាល័យរដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ដោយមានឋានៈស្មើអនុរដ្ឋលេខាធិការ ។

មាត្រា២.–នាយករដ្ឋមន្ត្រីទី១ និងនាយករដ្ឋមន្ត្រីទី២ នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ អោយបានសំរេច ។

មាត្រា៣.–ព្រះរាជក្រឹត្យនេះ ចូលជាធរមានច្បាប់ ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

ជា ស៊ីម

ព្រះរាជក្រឹត្យ ជស/រកត/១១៩៧/២៣៥

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ រាជវរោត្តម

ឧត្តមោស្សជាត បវិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤
- យោងតាមសំណើរបស់ប្រមុខរាជរដ្ឋាភិបាល ចុះថ្ងៃទី ២៨ ខែតុលា ឆ្នាំ១៩៩៧

ត្រាស់បង្គាប់

មាត្រា១.- តែងតាំងឯកឧត្តម គឹម ឈឿនម៉េង ជាទីប្រឹក្សាផ្ទាល់ឯកឧត្តមនាយករដ្ឋមន្ត្រីទី១ នៃរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកទំនាក់ទំនងរដ្ឋសភាជាតិ ដោយមានឋានៈស្មើអនុរដ្ឋលេខាធិការ ។

មាត្រា២.- នាយករដ្ឋមន្ត្រីទី១ និងនាយករដ្ឋមន្ត្រីទី២ នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ អោយបានសំរេច ។

មាត្រា៣.- ព្រះរាជក្រឹត្យនេះ ចូលជាធរមានច្បាប់ ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

ជា ស៊ីម

ព្រះរាជក្រឹត្យ នស/រកត/១១៩៧/២៧៦

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន

[illegible]

[illegible]

គឺព្រះចៅក្រុងកម្ពុជាធិបតី

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣ -

- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

- បានឃើញច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤

- យោងតាមសំណើរបស់ប្រមុខរាជរដ្ឋាភិបាល ចុះថ្ងៃទី ២៨ ខែតុលា ឆ្នាំ១៩៩៧

ត្រាស់បង្គាប់

មាត្រា១.- តែងតាំងឯកឧត្តម ឃី ថេង ជាទីប្រឹក្សាផ្ទាល់ឯកឧត្តមនាយករដ្ឋមន្ត្រីទី១ នៃរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកកិច្ចការរដ្ឋបាល ដោយមានឋានៈស្មើអនុរដ្ឋលេខាធិការ ។

មាត្រា២.- នាយករដ្ឋមន្ត្រីទី១ និងនាយករដ្ឋមន្ត្រីទី២ នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ អោយបានសំរេច ។

មាត្រា៣.- ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧

ក្នុងព្រះបរមនាម និងតាមព្រះរាជគ្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

ជា ស៊ីម

ព្រះរាជក្រឹត្យ នស/រកត/១១៩៧/២៣៧

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ រាជហរិវង្ស

ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតនៈ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី១៩ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ ១៩៩៤
- តាមសំណើរបស់ប្រមុខរដ្ឋស្តីទី ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ១៩៩៧

ត្រាស់បង្គាប់

មាត្រា១.- តែងតាំងឯកឧត្តម [illegible] ជាទីប្រឹក្សាផ្ទាល់ឯកឧត្តមនាយករដ្ឋមន្ត្រីទី១ នៃរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកកិច្ចការសង្គមកិច្ច មានឋានៈស្មើអនុរដ្ឋលេខាធិការ ។

មាត្រា២.- នាយករដ្ឋមន្ត្រីទី១ និងនាយករដ្ឋមន្ត្រីទី២ នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ អោយបានសំរេច ។

មាត្រា៣.- ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

នាយករដ្ឋមន្ត្រី	ប្រមុខរដ្ឋស្តីទី
[illegible]	ហត្ថលេខា
អ៊ឹង ហួត	ជា ស៊ីម

ព្រះរាជក្រឹត្យ ជស/រកត/១១៩៧/២៣៨

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ រាជហរិវង្ស

ឧភតោសុជាត ពិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤
- យោងតាមសំណើរបស់ប្រមុខរាជរដ្ឋាភិបាល ចុះថ្ងៃទី ២៨ ខែតុលា ឆ្នាំ១៩៩៧

ត្រាស់បង្គាប់

មាត្រា១.– តែងតាំងឯកឧត្តម **សេង ហុងហួរ** ជាទីប្រឹក្សាផ្ទាល់ឯកឧត្តមនាយករដ្ឋមន្ត្រីទី១ នៃរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកផ្នែកសំភារៈភស្តុភា ដោយមានឋានៈស្មើអនុរដ្ឋលេខាធិការ ។

មាត្រា២.– នាយករដ្ឋមន្ត្រីទី១ និងនាយករដ្ឋមន្ត្រីទី២ នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ អោយបានសំរេច ។

មាត្រា៣.– ព្រះរាជក្រឹត្យនេះ ចូលជាធរមានច្បាប់ ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

ជា ស៊ីម

ព្រះរាជក្រឹត្យ ជស/រកត/១១៩៧/២៤០

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ រាជហរិវង្ស

ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤
- យោងតាមសំណើរបស់ប្រមុខរាជរដ្ឋាភិបាល ចុះថ្ងៃទី ២៨ ខែតុលា ឆ្នាំ១៩៩៧

ត្រាស់បង្គាប់

មាត្រា១.– តែងតាំងលោកជំទាវ តាន់ ផល្លី ជាទីប្រឹក្សានៃរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកទំនាក់ទំនងសាធារណៈ ដោយមានឋានៈស្មើអនុរដ្ឋលេខាធិការ ។

មាត្រា២.– នាយករដ្ឋមន្ត្រីទី១ និងនាយករដ្ឋមន្ត្រីទី២ នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ អោយបានសំរេច ។

មាត្រា៣.– ព្រះរាជក្រឹត្យនេះ ចូលជាធរមានច្បាប់ ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

ជា ស៊ីម

ព្រះរាជក្រឹត្យ នស/រកត/១១៩៧/២៩១

យើង

[illegible]

[illegible]

[illegible]

នៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣ -

- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

- បានឃើញច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤

- យោងតាមសំណើរបស់ប្រមុខរាជរដ្ឋាភិបាល ចុះថ្ងៃទី ២៨ ខែតុលា ឆ្នាំ១៩៩៧ -

ត្រាស់បង្គាប់

មាត្រា១.- តែងតាំងលោកជំទាវ [illegible] ជាទីប្រឹក្សាផ្ទាល់ឯកឧត្តមនាយករដ្ឋមន្ត្រីទី១ នៃរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកកិច្ចការនារី ដោយមានឋានៈស្មើអនុរដ្ឋលេខាធិការ ។

មាត្រា២.- នាយករដ្ឋមន្ត្រីទី១ និងនាយករដ្ឋមន្ត្រីទី២ នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ អោយបានសំរេច ។

មាត្រា៣.- ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

ជា ស៊ីម

ព្រះរាជក្រឹត្យ នស/រកត/១១៩៧/២៤២

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ រាជហរិវង្ស

ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤
- យោងតាមសំណើរបស់ប្រមុខរាជរដ្ឋាភិបាល ចុះថ្ងៃទី ២៨ ខែតុលា ឆ្នាំ១៩៩៧

ត្រាស់បង្គាប់

មាត្រា១.– តែងតាំងលោកជំទាវ ទាវ ចន្ទថាណា ជាទីប្រឹក្សាផ្ទាល់ឯកឧត្តមនាយករដ្ឋមន្ត្រីទី១ នៃរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកកិច្ចការនារី ដោយមានឋានៈស្មើអនុរដ្ឋលេខាធិការ ។

មាត្រា២.– នាយករដ្ឋមន្ត្រីទី១ និងនាយករដ្ឋមន្ត្រីទី២ នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ អោយបានសំរេច ។

មាត្រា៣.– ព្រះរាជក្រឹត្យនេះ មានអានុភាពអនុវត្តចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

ជា ស៊ីម

[illegible]

[illegible]

[illegible]

ព្រះរាជក្រឹត្យ ជស/រកត/១១៩៧/២៤៥

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ រាជហរិវង្ស

ឧភតោសុជាត ពិសុទ្ធិពង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤
- យោងតាមសំណើរបស់ប្រមុខរាជរដ្ឋាភិបាល ចុះថ្ងៃទី ២៨ ខែតុលា ឆ្នាំ១៩៩៧

ត្រាស់បង្គាប់

មាត្រា១._ តែងតាំងលោក **សែ សាមុត** ជាសមាជិកក្រុមប្រឹក្សាភិបាល និងគណៈកម្មាធិការប្រតិបត្តិការមូលនិធិសង្គម ជំនួសលោក **អ៊ុង ឆឺត** ។

មាត្រា២._ នាយករដ្ឋមន្ត្រីទី១ និងនាយករដ្ឋមន្ត្រីទី២ នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ អោយបានសំរេច ។

មាត្រា៣._ ព្រះរាជក្រឹត្យនេះ ចូលជាធរមានច្បាប់ ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

ជា ស៊ីម

II-រាជរដ្ឋាភិបាល

សេចក្ដីសំរេច

សេចក្ដីសំរេចលេខ ៤៧ សសរ

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧

ស្ដីពីការបង្កើតគណៈកម្មការសំរបសំរួល ដើម្បីអភិវឌ្ឍន៍ផ្នែកផ្គត់ផ្គង់ទឹកស្អាត និងអនាម័យ

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញព្រះរាជក្រមឥ្យ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ១៩៩៣ ស្ដីពីការតែងតាំងនាយករដ្ឋមន្ត្រីទី១ និងនាយករដ្ឋមន្ត្រីទី ២
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែតុលា ឆ្នាំ១៩៩៤ និងព្រះរាជក្រមឥ្យលេខ នស/រកត/១០៩៤/៩០ ចុះថ្ងៃទី ៣១ ខែតុលា ឆ្នាំ១៩៩៤ ស្ដីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៨៩៧/១៤៧ ចុះថ្ងៃទី ០៧ ខែសីហា ឆ្នាំ ១៩៩៧ ស្ដីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- យោងតាមតំរូវការចាំបាច់

សំរេច

ប្រការ១ : បង្កើតគណៈកម្មការមួយមានឈ្មោះថា : « គណៈកម្មការសំរបសំរួលដើម្បីអភិវឌ្ឍន៍ផ្នែកផ្គត់ផ្គង់ទឹកស្អាតនិងអនាម័យ » ។

ប្រការ២ : គណៈកម្មការសំរបសំរួលដើម្បីអភិវឌ្ឍន៍ផ្នែកផ្គត់ផ្គង់ទឹកស្អាត និងអនាម័យ មានសមាសភាពដូចខាងក្រោម ៖

១_ឯកឧត្តម	**ពូ សុធីរៈ**	រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល	ប្រធាន
២_ឯកឧត្តម	**ខឹន គីមស្រេង**	អនុរដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន	អនុប្រធាន
៣_លោក	**យុន ខ៊ែត**	អគ្គនាយករងក្រសួងអភិវឌ្ឍន៍ជនបទ	អនុប្រធាន
៤_លោក	**ទន្សី ទិស្សុត**	អនុប្រធាននាយកដ្ឋានហិរញ្ញវត្ថុក្រៅប្រទេស នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ	សមាជិក
៥_លោក	**ហ៊ុំ ចំនួមន្ថា**	អនុប្រធាននាយកដ្ឋាននៃក្រសួងផែនការ	សមាជិក
៦_លោក	**នាយ ទ៉ាន់ឆន**	តំណាងទីស្តីការគណៈរដ្ឋមន្ត្រី	សមាជិក
៧_លោក	**ជា ស៊ុណា**	តំណាងក្រសួងបរិស្ថាន	សមាជិក
៨_លោក	**នេត មុន្នី**	តំណាងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា	សមាជិក
៩_លោក	**ពៀម សារ៉ន**	តំណាងសាលាក្រុងភ្នំពេញ	សមាជិក
១០_លោក	**ឯក សុនចាន់**	នាយករដ្ឋាករទឹកភ្នំពេញ	សមាជិក

ប្រការ៣ : គណៈកម្មការសំរបសំរួលដើម្បីអភិវឌ្ឍន៍ផ្នែកផ្គត់ផ្គង់ទឹកស្អាត និងអនាម័យ មានលេខាធិការដ្ឋាននៅក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ដែលមានប្រធាននាយកដ្ឋាន នៃក្រសួង ឧស្សាហកម្ម រ៉ែ និងថាមពល ជាប្រធានលេខាធិការដ្ឋាន ។

ប្រការ៤ : គណៈកម្មការនេះមានភារកិច្ច រៀបចំនយោបាយជាតិ និងសំរបសំរួលការងារដែលពាក់ព័ន្ធនឹងការអភិវឌ្ឍន៍ផ្នែកផ្គត់ផ្គង់ទឹកស្អាត និងអនាម័យ និងជាសមភាគីសំរាប់សំរបសំរួល

ការងារជាមួយធនាគារពិភពលោក ព្រមទាំងធ្វើរបាយការណ៍រៀងរាល់ត្រីមាស ស្តីពីការរីកចំរើនលើការងារនេះជូនរាជរដ្ឋាភិបាល ។

ប្រការ៥ : សមាជិកនៃគណៈកម្មការនេះត្រូវចូលរួមប្រជុំ និងអនុវត្តការងារតាមសេចក្តីអញ្ជើញ និងការណែនាំរបស់ប្រធាន និងប្រើប្រាស់ត្រារបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ដើម្បីសំរួលការងារ ។

ប្រការ៦ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងផែនការ រដ្ឋមន្ត្រីក្រសួងបរិស្ថាន ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្រសួង-ស្ថាប័ន និងឯកឧត្តម អស់លោក ដែលមានឈ្មោះក្នុងប្រការ ២ មានភារកិច្ចអនុវត្តសេចក្តីសំរេចនេះ អោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី១ **នាយករដ្ឋមន្ត្រីទី២**

ហត្ថលេខា និងត្រា

ឹង ហួត **ហ៊ុន សែន**

* * *

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧

សេចក្តីសំរេចលេខ ៤៨ សសរ

ស្តីពីការផ្ទេរសិទ្ធិ

* * *

រាជរដ្ឋាភិបាល

– បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣

– បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែតុលា ឆ្នាំ១៩៩៤ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៩០ ចុះថ្ងៃទី ៣១ ខែតុលា ឆ្នាំ១៩៩៤ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៨៩៧/១៤៧ ចុះថ្ងៃទី ០៧ ខែសីហា ឆ្នាំ ១៩៩៧ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល
- តាមសំណូមពររការងារចាំបាច់

សំរេច

ប្រការ១ : ផ្ទេរសិទ្ធិជូនឯកឧត្តម **ស ខេង** និងឯកឧត្តម **អ៊ឹង ហ៊ួត** ឧបនាយករដ្ឋមន្ត្រី ជានាយករដ្ឋមន្ត្រីស្តីទី ចាប់ពីថ្ងៃទី ១៣ ខែវិច្ឆិកា ឆ្នាំ១៩៩៧ រហូតដល់ឯកឧត្តមនាយករដ្ឋមន្ត្រីទី១ និង សម្តេចនាយករដ្ឋមន្ត្រីទី២ វិលត្រឡប់មកពីបំពេញបេសកកម្មនៅឯបរទេសវិញ ។

ប្រការ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីគ្រប់ក្រសួង រដ្ឋលេខាធិការ គ្រប់រដ្ឋលេខាធិដ្ឋាន ឯកឧត្តមឧបនាយករដ្ឋមន្ត្រី **ស ខេង** និងឯកឧត្តមឧបនាយករដ្ឋមន្ត្រី **អ៊ឹង ហ៊ួត** ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសំរេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី១ **នាយករដ្ឋមន្ត្រីទី២**

ហត្ថលេខា និងត្រា

អ៊ឹង ហួត **ហ៊ុន សែន**

III-ការងារបណ្ដាក្រសួង

១_ទីស្ដីការគណៈរដ្ឋមន្ត្រី

សេចក្ដីសំរេច

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧

សេចក្ដីសំរេចលេខ ១៨ សសរ

ស្ដីពីការបង្កើតច្រកទ្វារអន្តរជាតិ

នៅអាកាសយានដ្ឋាន ខេត្តសៀមរាប

* * *

សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ប្រកាសអោយប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកត/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ប្រកាសអោយប្រើច្បាប់ ស្ដីពីការបង្កើតទីស្ដីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ៤៥ អនក្រ.បក ចុះថ្ងៃទី ២៩ ខែសីហា ឆ្នាំ ១៩៩៧ ស្ដីពីការរំសាយ និងការបង្កើតទីស្នាក់ការត្រួតពិនិត្យតាមច្រកព្រំដែន និងផ្លូវគមនាគមន៍នៅទូទាំងព្រះរាជាណាចក្រកម្ពុជា
- តាមការឯកភាពរបស់ឯកឧត្តមនាយករដ្ឋមន្ត្រីទី១ ចុះថ្ងៃទី ១១ ខែវិច្ឆិកា ឆ្នាំ១៩៩៧ និងការឯកភាពរបស់សម្ដេចនាយករដ្ឋមន្ត្រីទី២ ចុះថ្ងៃទី ០៤ ខែវិច្ឆិកា ឆ្នាំ១៩៩៧

សំរេច

ប្រការ១ : បង្កើតច្រកទ្វារអន្តរជាតិ នៅអាកាសយានដ្ឋានខេត្តសៀមរាប ។

ប្រការ២ : សមាសភាពគណៈកម្មការ សំរាប់គ្រប់គ្រងអាកាសយានដ្ឋានខេត្តសៀមរាបមានដូចតទៅ ៖

១_តំណាងអាជ្ញាធរអាកាសចរស៊ីវិល ប្រធាន
២_តំណាងនគរបាលជាតិ ផ្នែកអន្តោប្រវេសន៍ អនុប្រធាន
៣_តំណាងមន្ត្រីភ្នាក់ងារគយ និងរដ្ឋាករ សមាជិក
៤_តំណាងមន្ត្រីភ្នាក់ងារកាំកុងត្រូល សមាជិក
៥_តំណាងមន្ត្រីភ្នាក់ងារ ក្រសួងទេសចរណ៍ សមាជិក
៦_តំណាងអាជ្ញាធរខេត្តសៀមរាប សមាជិក

ប្រការ៣ : ដោយបច្ចុប្បន្នថវិការរដ្ឋកំពុងជួបការលំបាកយ៉ាងខ្លាំង អាជ្ញាធរអាកាសចរស៊ីវិល ត្រូវខិតខំរកប្រភពថវិកាចំនួន ៥០០ ពាន់ (ប្រាំពាន់)ដុល្លារអាមេរិក ដោយខ្លួនឯងសំរាប់ធ្វើការជួសជុល និងបំពាក់ឧបករណ៍អោយដល់អាកាសយានដ្ឋានខេត្តសៀមរាប ដោយមិនចាំបាច់ធ្វើការដេញថ្លៃលើគំរោងការងារនេះទេ ដើម្បីដំណើរការអោយយន្តហោះចុះចតបានឆាប់ និងប្រកបដោយសុវត្ថិភាព ។

ប្រការ៤ : ការអនុវត្តន៍ ការបើកច្រកទ្វារអន្តរជាតិនៅអាកាសយានដ្ឋានខេត្តសៀមរាបនេះ ត្រូវធ្វើតាមលទ្ធភាព និងមិនត្រូវអោយមានការប៉ះពាល់ដល់ខ្លឹមសារដែលមានចែងក្នុងកិច្ចសន្យា ស្តីពីការសាងសង់អាកាសយានដ្ឋានអន្តរជាតិពោធិចិនតុង ជាមួយក្រុមហ៊ុន DUMEZ និងគុណាទានរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ។

ប្រការ៥ : ក្នុងជំហានដំបូង អាកាសយានដ្ឋានខេត្តសៀមរាប អនុញ្ញាតអោយចុះចតតែយន្តហោះប្រភេទកង្ហារ ដែលដឹកភ្ញៀវទេសចរណ៍មកពីប្រទេសថៃ ឡាវ វៀតណាម ភូមា និងភាគខាងត្បូងប្រទេសចិន ។

ប្រការ៦ : តួនាទី ភារកិច្ច សិទ្ធិអំណាច ការផ្លាស់ប្តូរ និងការដាក់ពិន័យរបស់មន្ត្រីភ្នាក់ងារ និងកងកំលាំងប្រដាប់អាវុធមានសមត្ថកិច្ចប្រចាំការនៅអាកាសយានដ្ឋានខេត្តសៀមរាប ត្រូវអនុវត្តតាមខ្លឹមសារដែលមមានចែងក្នុងមាត្រា៤ មាត្រា៩ មាត្រា១០ និងមាត្រា១១ នៃអនុក្រឹត្យលេខ ៤៥ អនក្រ.បក ចុះថ្ងៃទី ២៩ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការរិសាយ និងការបង្កើតទីស្នាក់ការត្រួតពិនិត្យតាមច្រកទ្វារព្រំដែន និងផ្លូវគមនាគមន៍នៅទូទាំងព្រះរាជាណាចក្រកម្ពុជា ។

ប្រការ៧ : អភិបាលខេត្តសៀមរាប រួមជាមួយអាជ្ញាធរអាកាសចរស៊ីវិល ត្រូវដាក់ចេញនូវបទបញ្ញាត្តិពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អាកាសយានដ្ឋានខេត្តសៀមរាប និងសហការសំរបសំរួលលើរាល់ ដើម្បីធ្វើអោយការងារទីនេះ មានដំណើរការបានរលូនសមស្របតាមសំណូមពររបស់ភ្ញៀវជាតិ និងអន្តរជាតិ ។

ប្រការ៨ : បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីសេចក្តីសំរេចនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ៩ : ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងពាណិជ្ជកម្ម បណ្តាក្រសួង ស្ថាប័នពាក់ព័ន្ធ សាលាខេត្តសៀមរាប និងសាមីខ្លួន ដែលចែងក្នុងប្រការ២ ត្រូវទទួលអនុវត្តសេចក្តីសំរេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

សុខ អាន

....

២_ទីស្តីការរដ្ឋមន្ត្រីក្រសួងពត៌មាន

ប្រកាស

រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧

ប្រកាសលេខ ៣០១/៩៧ ពម.ប្រក

ស្តីពីការផ្ទេរ តែងតាំងមន្ត្រីរាជការ

***

រដ្ឋមន្ត្រីក្រសួងពត៌មាន

– បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣

– បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

_បានឃើញព្រះរាជក្រមលេខ ០២ នស ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

_បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៤ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតក្រសួងពត៌មាន

_យោងតាមសំណើរបស់នាយកដ្ឋានមណ្ឌលពត៌មាន

_ពិនិត្យលើលក្ខណៈសម្បត្តិ និងសមត្ថភាពមន្ត្រីរាជការ

សំរេច

ប្រការ១ : តែងតាំងមន្ត្រីរាជការចំនួន ០៣ នាក់ ជាប្រធានការិយាល័យ និងអនុប្រធានការិយាល័យ នាយកដ្ឋានមណ្ឌលពត៌មាន នៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ ក្រសួងពត៌-មាន ដូចមានរាយនាមខាងក្រោមនេះ ÷

១_លោក **គៀន ណារិទ្ធ** ជាប្រធានការិយាល័យគ្រប់គ្រងកាសែតក្នុងស្រុក

២_កញ្ញា **តិត្យ កល្យាណី** ជាអនុប្រធានការិយាល័យគ្រប់គ្រងកាសែតក្នុងស្រុក

៣_អ្នកស្រី **ងីម សុមី** ជាអនុប្រធានការិយាល័យសំរបសំរួលពាក្យបណ្តឹង

ប្រការ២ : ផ្ទេរលោក **ហ៊ុនធីរៈ** ពីប្រធានការិយាល័យគ្រប់គ្រងការសែតក្នុងស្រុក អោយទៅកាន់ការងារជាប្រធានការិយាល័យសំរបសំរួលពាក្យបណ្តឹង នៃនាយកដ្ឋានមណ្ឌលពត៌មានវិញ។

ប្រការ៣ : ឯកឧត្តមអគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ លោកនាយកខុទ្ទកាល័យ គ្រប់អគ្គនាយកដ្ឋានចំណុះប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានផែនការគណនេយ្យ ហិរញ្ញ កិច្ច និងអស់លោក នាងកញ្ញា ក្នុងប្រការ១ និងប្រការ២ ត្រូវអនុវត្តតាមប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខានិងត្រា

ខៀវ កាញារីទ្ធ

៣_នីស្តីការក្រសួងធម្មការនិងសាសនា

ប្រកាស

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧

ប្រកាសលេខ ២២២/៩៧ កធស.ប្រក

ស្តីពីការតែងតាំងមន្ត្រីរាជការ

* * *

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣
- បានឃើញព្រះរាជក្រមលេខ នស/រកត/០១៩៦/១៩ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងធម្មការ និងសាសនា
- បានឃើញច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា លេខ ០៦ នស/៩៤ ចុះថ្ងៃទី ៣០ ខែតុលា ឆ្នាំ១៩៩៤
- បានឃើញអនុក្រឹត្យលេខ ២២ អនក្រ ចុះថ្ងៃទី ៣០ ខែមិថុនា ឆ្នាំ១៩៩២ ដែលរៀបចំ និងប្រព្រឹត្តិទៅនៃក្រសួងធម្មការ និងសាសនា
- បានឃើញលិខិតលេខ ៤៦ ស.ល ចុះថ្ងៃទី ០៣ ខែកក្កដា ឆ្នាំ ១៩៩៧ របស់សាលាខេត្ត ព្រះវិហារ

សម្រេច

ប្រការ១ : លោក **ថ្នាំ ស៊ុ** បច្ចុប្បន្នជាប្រធានមន្ទីរស្ថិតិ ត្រូវបានតែងតាំងជាប្រធានមន្ទីរពេញសិទ្ធិនៃមន្ទីរធម្មការ និងសាសនាខេត្តព្រះវិហារ ជំនួសលោក **ហុក ឡឿន** «ដោយទទួលមរណភាព» ។

ប្រការ២ : ប្រភេទកាំបៀវត្ស និងប្រាក់ឧបត្ថម្ភផ្សេងៗប្រគល់ជូនមន្ទីរធម្មការ និងសាសនាខេត្ត ជាអ្នករៀបចំ និងចាត់ចែង ។

ប្រការ៣ : ខុទ្ទកាល័យ នាយកដ្ឋានរដ្ឋបាល និងហិរញ្ញកិច្ច «ការិយាល័យបុគ្គលិក ការិយាល័យគណនេយ្យ » មន្ទីរធម្មការ និងសាសនាខេត្ត មន្ទីរផែនការខេត្ត មន្ទីរហិរញ្ញវត្ថុខេត្តព្រះវិហារ និងលោក ព្រាំ ស៊ូ ត្រូវអនុវត្តរៀងៗខ្លួនតាមប្រកាសនេះ ។

ប្រការ៤ : ប្រកាសនេះមានប្រសិទ្ធិភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋលេខាធិការក្រសួងធម្មការ និងសាសនា

ហត្ថលេខា និងត្រា

ហឿន វណ្ណារិន្ទ

បោះពុម្ពនៅរោងពុម្ព ទីស្តីការគណៈរដ្ឋមន្ត្រី

លើកទី១ ចំនួន ៥០០ ច្បាប់

តម្លៃ ២៧៨០ រៀល